D24942

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ហ៊ឹម ហ៊ុយ

## នៅភូមិអន្លុងសាន ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល

## ថ្ងៃទី៩ ខែមករា ឆ្នាំ២០០៣

## សម្ភាសន៍ដោយ ប៉ាំង ពីរីន និង ស៊ិន ឃិន

ហ៊ុយ៖ វាយគ្នាបែបតាំងពីឆ្នាំ៧១

ឃិន៖ ចូលរបប លន់ ណុល?

ហ៊ុយ៖ កាលហ្នឹងគេអត់ទាន់ហៅខ្មែរក្រហមទេ គេហៅខ្មែររំដោះ

ពីរីន៖ ពូអាចនិយាយប្រាប់ខ្ញុំបានទេ ពីដំណើររឿងរ៉ាវរបស់ពូ តាំងពីពូចេញពីភូមិទៅ?

ហ៊ុយ៖ ខ្ញុំកាលដំបូងបំផុតនៅឆ្នាំ៧០នៅរៀន ដល់ ឈប់រៀន ឪពុកម្ដាយខ្ញុំឈឺ ក៏ឈប់រហូតដល់ចុងឆ្នាំ៧៣ ក្នុងការតឹងតែងរបស់គេ គេប្រមូលយុវជនដែលនៅតាមភូមិទាំងអស់ អត់មាននរណានៅទេ ទៅទ័ព គេរើសទៅទ័ព ហើយខ្ញុំគេរើសយកមកធ្វើកងទ័ពស្រុកនេះ ហៅថាទាហាននៅស្រុក ដល់ហាត់យូរអាឡូយផ្ទះ សុំគេទៅផ្ទះគេអត់ឲ្យទៅៗ ក្រោយមកទៀតមិនដឹងនិយាយយ៉ាងម៉េចទេ អាឡូយមែនទែន សឹងតែរត់ទៅផ្ទះវិញ ដល់មកពួកគេ ពួកគណៈសាលាគេផ្ដាំមកថាម៉ែឪឈឺ សុំគេទៅមើល គេអត់ឲ្យទៅទៀត គេថាខ្ញុំមិនមែនពេទ្យទេ បើខ្ញុំពេទ្យចាំទៅមើល តែបើមិនមែនពេទ្យ មិនបាច់ទៅមើលទេៗ ការតឹងតែងរបស់គេមិនឲ្យទៅផ្ទះទេ ខ្ញុំនៅៗរហូត ដល់ហើយបានគេបញ្ជូនពួកខ្ញុំហ្នឹងមកនៅកងទ័ពភូមិភាគពិសេស បញ្ចូលទៅក្នុងកងទ័ពភូមិភាគពិសេស កាលហ្នឹងគេហៅកងវរ១១២ កងវរសេនាតូច១១២ ប្រចាំភូមិភាគពិសេស នៅរហូតដល់ឆ្នាំ ដល់ច្បាំងឈ្នះភ្នំពេញឆ្នាំ៧៥ ដល់ក្រោយមកឆ្នាំប៉ុន្មានទេ ទៅកងវិញគេផ្លាស់មកនៅ១៨៣ កងពិសេសប្រចាំកងពល៧០៣ ត្រូវរបួស ដេកពេទ្យរហូតចេញទៅវិញ គេឲ្យពួកកងខ្ញុំនៅយាមរដ្ឋករទឹកល្អក់យាមហ្នឹង យាមផងធ្វើស្រែផងនៅមួយជំនាវ រោងចក្រអគ្គីសនីចាក់អង្រែ ជំរាលដីនៅហ្នឹងៗ ក្រោយមកទៀតគេដកមកធ្វើស្រែនៅព្រែកជ្រៅតាខ្មៅ ដល់ហើយបានគាហ៍ នៅទួលឥឡូវ កងវររបស់ខ្ញុំ

កាលមុនជួបគ្នានៅទួលស្លែងអញ្ជឹងដែរ ហ៊ា ថាឲ្យខ្ញុំទៅផ្លាស់អង្គភាពទៅនៅកងទ័ពអាមេរិន មានអីមានតែបាឡូវ១ និងខោអាវ២-៣កំផ្លេរហ្នឹង ទៅ ដល់ទៅ ទៅដល់កន្លែងនេះ ផ្ទះគាត់ផ្សារថ្មី យប់បានគាត់ឌុបកង់យកមកខ្ញុំស្មានតែគាត់ឲ្យខ្ញុំផ្លាស់អង្គភាពដល់ហើយម៉ោង៨បានខ្ញុំមក ហ៊ុយឯងមានដឹងខ្លួនឯងមានរឿងអីអត់? ហាស ក្រែងបងឯងឲ្យខ្ញុំទៅកង ខ្ញុំអត់ដឹងមានរឿងអីទេបង ទៅដល់នោះគង់តែដឹងទេបង ខ្ញុំនឹកឃើញខ្លួនខ្ញុំកាលនៅទ័ពធ្លាប់រត់មកផ្ទះ២-៣សារហើយ ហើយចូលសាលាសេរី៣ដងសង្ស័យរឿងហ្នឹងហើយចេះតែទៅជាមួយគេ ហើយមកចេះតែមកជាមួយគាត់ទៅមកមកនៅកន្លែង៣-៤ថ្ងៃ គេឲ្យនៅតែស្ងៀម ក្រោយមកបានគេឲ្យយាមនៅហ្នឹងយាមចេះតែយាមអីទៅ កាលមុននៅហ្នឹងនៅច្រើនដែរ ២កងរយមុន ប្រមូលកម្លាំងយកមកសុំពូអង្គភាពយកមក ហើយកងរយគ្នាច្រើនណាស់កាលហ្នឹង ហើយខ្ញុំអត់បានធ្វើកងរយអីគេទេ ដល់យូរទៅវា ឆ្នាំ៧៧ ៧៦ជាង ៧៧ គេចេះតែតឹងតែងចាប់ចូលដកអាអ្នកក្នុងហ្នឹង ដាក់គុកអីពេញហ្នឹង អាកងរយក៏អស់ អាអ្នកសួរចម្លើយក៏អស់ដល់អញ្ជឹងទៅអស់កងរយ កងអី ក៏ឲ្យខ្ញុំឡើងកងរយបណ្ដោះអាសន្ននៅកន្លែងហ្នឹងហើយខ្ញុំក្រោយមកគេឲ្យខ្ញុំទៅសួរចម្លើយ ខ្ញុំអំសួរ ព្រោះខ្ញុំពិបាកគិតពិបាកគួរណាស់សួរមិនត្រូវពិបាក ហើយនៅកន្លែងហ្នឹងអត់ដឹងទេ អត់ដឹងមានរឿងអីទេ អញ្ជឹងសុខចិត្តនៅខាងក្រៅនៅយាមអី ដល់យូរឲ្យខ្ញុំនៅខាងទទួលមនុស្ស ទទួលអ្នកទោសហ្នឹង ដើរចាប់ ដើរចងអី ទៅជាមួយគេ ហើយខ្ញុំនៅកន្លែងទទួលមនុស្សនៅក្រៅហ្នឹង ដើរទៅណាទៅណីទៅជាមួយគេ ខ្ញុំដឹង ៗ ដល់ក្រោយមកទៀត ដកពួកខ្ញុំទៀតហើយ ពាក់កណ្ដាលឆ្នាំ៧៨ ដកមកធ្វើស្រែនៅបឹងជើងឯក គេលែងឲ្យទៅអំពេញ លែងដឹងរឿងគេហើយ បែកហើយក៏គេមកប្រមូលពួកខ្ញុំទៅទៀត ទៅព្រៃទៀត ៗ ទៅខ្ញុំរៀបចំកម្លាំងវាយជាមួយវៀតណាម វាយជាមួយខ្មែរយើង វាយចុះវាយឡើងខ្ញុំរត់មកណេះបណ្ដោយ ៗ

ពីរ៉ិនៈ លោកពូខ្ញុំសុំសួរបកទៅសំនួរមុន ៗ ៗ ពេលពូចូល តើពូចង់ទៅខ្លួនឯងឬយ៉ាងម៉េច?

ហ៊ុយៈ កំណែនគេគេណ្ហូទៅហ្នុង

ពីរ៉ិនៈ ទៅនឹងមានប៉ុន្មាននាក់ចេញទៅដូចលោកពូ?

ហ៊ុយៈ ខ្ញុំវាទូចដែរ ខ្ញុំនៅភូមិ គ្នាមិនបាន១០នាក់ទេ ភូមិហ្នឹង ហើយទៅនារីក៏គេប្រមូលទៅដែរ ៗ ហើយទៅបែកគ្នារហូត ពីកន្លែងភូមិមកស្រុក ពីឃុំមកស្រុកបែកគ្នារហូត

មកខាងទំពស្រុកផង បញ្ជូនទៅភូមិភាគពិសេសផង បែកគ្នាទាំងអស់ អត់មាននៅជាមួយគ្នាទេ ។

ពីរីនៈ កាលហ្នឹងគេប្រមូលអ្នកអាយុប៉ុន្មានពូ,

ហ៊ុយៈ កាលហ្នឹងមិនដឹងអាយុប៉ុន្មានទេ ប្រហែល១៦-១៧

ពីរីនៈ ចុះពូចេញទៅអាយុប៉ុន្មាន?

ហ៊ុយៈ ១៦-១៧

ពីរីនៈ ពូចេញទៅធ្វើអីនៅណា?

ហ៊ុយៈ ចេញពីផ្ទះទៅ គេឲ្យនៅហាត់ នៅកន្លែងព្រៃកឈើមជិតមន្ទីរស្រុកកោះធំកើត

ពីរីនៈ ហាត់អីគេពូ?

ហ៊ុយៈ ហាត់យោធាហ្នឹង

ពីរីនៈ ហើយគេមានបង្រៀនទ្រឹស្តីអីដែរអត់?

ហ៊ុយៈ គេបង្រៀននយោបាយអីគេហ្នឹង

ពីរីនៈ ហាត់នៅហ្នឹងរយៈពេលប៉ុន្មានខែពូ?

ហ៊ុយៈ មិនដឹងប៉ុន្មានខែដែរ ប្រហែលជាកន្លះខែ

ពីរីនៈ ចេញពីហ្នឹងមកទៅណាទៀត?

ហ៊ុយៈ ចេញពីហ្នឹងមកគេបញ្ជូនឲ្យដើរតាមផ្លូវហ្នឹងរហូត នៅជិតវត្តខ្ពបក្រោម

ពីរីនៈ ទៅធ្វើអី ?

ហ៊ុយៈ អាហ្នឹងគេចេះតែបញ្ជូនទៅ ហើយបាន២-៣ថ្ងៃ គេបញ្ជូនឲ្យទៅនៅឈើខ្មៅទៀត ខ្ញុំហាត់រៀនហ្នឹង ម្ល៉ោះហើយ២នាក់ជីដូនមួយនាំគ្នារត់ទៅផ្ទះ អាឡូយផ្ទះពេក អត់សុំគេទេ ទៅហ្នឹង បើសុំគេ គេមិនឲ្យទៅ ហើយថ្ងៃនេះយន្តហោះទម្លាក់ទៀត ចូលផ្ទះបាន១យប់ ។

ពីរីនៈ ជីដូនមួយពូឈ្មោះអី?

ហ៊ុយៈ ឈ្មោះ ញាង

ពីរីនៈ ហើយឥឡូវនៅណា?

ហ៊ុយៈ គេរកស៊ីបើឡាននៅអំពេញ នៅដល់ណាទៀតទេ

ពីវ៉ន: យន្តហោះទម្លាក់របៀបម៉េចលោកពូ?

ហ៊ុយ: កាលហ្នឹងទម្លាក់យន្តហោះពីភ្នំពេញមកខាង លន់ ណុល ទម្លាក់ ហើយគណៈសាលា ថាបើខ្ញុំមកវិញគេឲ្យកងហា អីមើលខ្ញុំដាក់ទណ្ឌកម្មរែកឲ្យបាន២អម្រែក ៣ពាងម្នាក់៦ង រែកទឹកឲ្យបាន៣ពាង អត់ឲ្យទៅណាទេ ប្រហែលស្មាហ្នឹងគេហៅទៅសួរ គេផ្ទែកកាំភ្លើង ៣ដើម ហែងស្រឡាញ់កាំភ្លើងមួយណារើសទៅ? ខ្ញុំថាមិនដឹងស្រឡាញ់មួយណាទេ បើសុទ្ធតែបាញ់ងាប់ទាំងអស់ និយាយតែប៉ុណ្ណឹង ហើយមកវិញគេដាក់ទណ្ឌកម្មឲ្យរែក ទឹកឲ្យពេញពាង គេថាបើយន្តហោះមកទម្លាក់ទៀត គេចាប់ខ្ញុំ២នាក់ហ្នឹងមកដាក់នៅ កន្លែងហ្នឹងឲ្យយន្តហោះបាញ់ចោល គេថាខ្ញុំវាអ្នកឲ្យសញ្ញាទៅគេ ហើយខ្ញុំអត់ដឹងទេ ខ្ញុំអាឡ័យម៉ែឪពេក ៗ ព្រោះថាខ្ញុំឲ្យសញ្ញាឲ្យគេ ហើយខ្ញុំអត់ដឹងទេ ខ្ញុំអាឡ័យម៉ែឪ ពេក ៗ

ឃិន: ទម្លាក់ក្បែរហ្នឹងជិតទេ?

ហ៊ុយ: ជិតដែរ ប្រហែលជា២-៣គីឡូទេ

ពីវ៉ន: កាលហ្នឹងពូមកផ្ទះបានប៉ុន្មានថ្ងៃ?

ហ៊ុយ: មកដេកបាន១យប់

ពីវ៉ន: ពូទៅវិញខ្លួនឯងឬក៏ ?

ហ៊ុយ: មកវិញខ្លួនឯង

ពីវ៉ន: ម៉េចបានពូទៅវិញ?

ហ៊ុយ: បើមិនទៅវិញគេមកចងដល់ផ្ទះ

ពីវ៉ន: គេដាក់ទណ្ឌកម្មពូហើយ គេបញ្ជូនពូទៅណាទៀត?

ហ៊ុយ: គេដកកម្លាំងឡើងមកនៅវត្តកំពង់សប្បូរ

ឃិន: គេអត់មានឲ្យកាន់កាំភ្លើងអីទេ?

ហ៊ុយ: ទាំងអស់គ្នាអត់មានកាំភ្លើងទេ មានកងហា មានអី

ពីវ៉ន: អញ្ចឹងទៅដល់ពូអត់ទាន់មាននាទីធ្វើអីទេ?

ហ៊ុយ: នៅទេ ដល់ហើយបានទៅដល់កំពង់សំបូរខ្ញុំដាំឲ្យម៉ែឪខ្ញុំសុំគេ ដល់សុំគេអត់ឲ្យទៅផ្ទះទេ ៗ ទៅតាមគេគេដកពីហ្នឹងទៅទៀត ទៅព្រៃកល្វា ដកទៅព្រៃកល្វា គេចែកកម្លាំងទៅ អង្គភាពរបស់វា អង្គភាព៧៣

ពីវ៉ិនៈ កងពលលេខប៉ុន្មានពូ?

ហ៊ុយៈ កាលហ្នឹងគ្មានកងពលទេ គ្រាន់តែវរសេនាតូច១១២ វរសេនាធំប៉ុន្មានទេ ភ្លេចហើយ អាណឹងកងទ័ពប្រចាំភូមិភាគពិសេស

ពីវ៉ិនៈ ហើយពូទៅណាទៀត?

ហ៊ុយៈ ចេញពីនេះទៅ ទៅដីវិស្លាប់ ទ័ពគេបោះទីតាំងនៅហ្នឹង នៅក្រាំងយ៉ូវ នៅអី

ឃិនៈ ពេលនោះពូមានសិទ្ធិកាន់កាំភ្លើងហើយ?

ហ៊ុយៈ បាទ

ពីវ៉ិនៈ ពូទៅហ្នឹងធ្វើអី?

ហ៊ុយៈ គេបញ្ជូនឲ្យទ័ពនៅហ្នឹង តាមទ័ពគេ

ពីវ៉ិនៈ ពូនៅហ្នឹងរយៈពេលប៉ុន្មានខែ?

ហ៊ុយៈ មិនដឹងប៉ុន្មានខែទេ បន្តិចនៅភូមិនេះ បន្តិចនៅក្នុងព្រៃ វាចេះតែឲ្យនៅ

ពីវ៉ិនៈ ចេញពីហ្នឹងទៅណាទៀត?

ហ៊ុយៈ ចេញពីហ្នឹងគេឲ្យទៅវាយនៅផ្លូវជាតិលេខ២

ពីវ៉ិនៈ គ្នាពូមានប៉ុន្មាននាក់ពូ?

ហ៊ុយៈ កាលហ្នឹងមួយកងរយ កងរយច្រើនៗគ្នាដែរ ៣-៤០០នាក់

ពីវ៉ិនៈ ចេញពីផ្លូវជាតិលេខ២ទៅណា?

ហ៊ុយៈ មកវាយទន្លេនេះទៀត

ពីវ៉ិនៈ ទន្លេអីគេ?

ហ៊ុយៈ ផ្លូវជាតិលេខ២១ ហើយបានទៅវាយនៅទន្លេមេគង្គទៀត

ពីវ៉ិនៈ ទៅណាទៀត?

ហ៊ុយៈ ទៅទន្លេមេគង្គ ហើយបានទៅទន្លេបាសាក់វិញ

ពីវ៉ិនៈ ពូមកដល់ណាទៀត?

ហ៊ុយៈ ទន្លេបាសាក់ហើយបានវាយចូលអំពេញ

ពីវ៉ិនៈ នៅឆ្នាំណាពូ?

ហ៊ុយៈ នៅឆ្នាំ៧៥

ពីវ៉ិនៈ ពូចូលអំពេញមាននាទីធ្វើអីដែរនៅអំពេញ?

ហ៊ុយៈ វាវាយទ័ពពីនេះចូលអំពេញ

ពីវីនៈ ធ្វើអី?

ហ៊ុយៈ មានទាន់ធ្វើអី

ពីវីនៈ ចុះពូនៅអំពេញបានប៉ុន្មានឆ្នាំ?

ហ៊ុយៈ មិនដឹងប៉ុន្មានឆ្នាំទេ

ពីវីនៈ គេឲ្យពូធ្វើអីខ្លះនៅអំពេញ?

ហ៊ុយៈ យាមអាកន្លែងអគ្គីសនីទឹកនៅអំពេញហ្នឹង

ពីវីនៈ នៅម្តុំណា?

ហ៊ុយៈ កន្លែងម៉ាស៊ីនបូមទឹកកន្លែងទឹកល្អក់ហ្នឹង

ពីវីនៈ ពូយាមនៅហ្នឹងរយៈពេលប៉ុន្មានខែ?

ហ៊ុយៈ មកធ្វើស្រែ ធ្វើអី

ឃិនៈ នៅណា?

ហ៊ុយៈ នៅកន្លែងក្រោយអគ្គីសនីចាក់អង្រែ បានមកកន្លែងព្រែកជ្រៅទៀត ដកខ្ញុំពីហ្នឹងយក ទៅអំពេញ ទៅផ្លាស់អន្តភាពយកខ្ញុំទៅកន្លែងគុកហ្នឹង

ពីវីនៈ មូលហេតុអីបានគេហៅពូទៅកន្លែងទួលស្លែង?

ហ៊ុយៈ អត់ដឹងទេ

ពីវីនៈ ពូទៅកន្លែងហ្នឹងនៅឆ្នាំណា?

ហ៊ុយៈ ឆ្នាំ៧៦ ៧៧ ហើយ ដើមឆ្នាំ៧៧ នៅចុងឆ្នាំ៧៦ ជិតអីហ្នឹង

ពីវីនៈ ចុះពូថាពូត្រូវរបួស ដេកពេទ្យនៅឆ្នាំណា?

ហ៊ុយៈ នៅក្នុងឆ្នាំ៧៥

ពីវីនៈ ដេកពេទ្យនៅណា?

ហ៊ុយៈ នៅព្រែកប៉ុកនេះ ស្អាង

ពីវីនៈ កាលហ្នឹងអត់ទាន់បែកអំពេញណាហី?

ហ៊ុយៈ បែកហើយ

ពីវីនៈ ចុះ៧៦ ពូទៅណា?

ហ៊ុយៈ ដូចខ្ញុំជំរាបអញ្ចឹង គេឲ្យធ្វើស្រែ ធ្វើអី

ពីវីនៈ ចុះពូថា ហ៊ា ហៅទៅប្រជុំ

ហ៊ុយៈ អាហ្នឹងខ្ញុំមកដើង៦កហើយ

ពីវ៉ន: ហេតុអីបាន ហ៊ា ហៅពូទៅប្រជុំ?

ហ៊ុយ: អត់ដឹងដែរ ព្រោះថ្ងៃហ្នឹងទេប្រជុំតែម្នាក់ឯង គេចូលម៉ោង៨ គេយកអាស៊ីបមួយ មកហៅខ្ញុំទៅ ខ្ញុំមិនដឹងយ៉ាងម៉េចទេ ទៅប្រជុំមានគ្នាតែប៉ុន្មាននាក់ តែបងងងី ប៉េង ខ្ញុំ គ្នា៤នាក់ ហើយ ហ៊ា ហ្នឹង ប្រជុំចំអាក្មេងទ្វាមួយពីមុខ ផ្ទះនៅកើតផ្លូវ ។ ហើយខ្ញុំ ទៅដល់ដូចដំណើរវាមិនស្រួលធ្លាប់ចាប់គេអញ្ចឹង ដូចទំនងមិនល្អ បែបចាប់ហើយ ច្បាស់ជាចាប់ហើយ ភ័យមែនទែន ហើយប៉េងមាឌធំ ហៅខ្ញុំហៅ២-៣សារខ្ញុំអត់ ព្រមចូល បើមិនចូលក៏ត្រូវតែជាប់ ហើយជៀសមិនរួច ខ្ញុំមែនទែនទៅអង្គុយផ្អែកកន្លែង ផ្ទះថ្ម ខ្ញុំថាខ្ញុំឈឺអស់មែនទែន ថាឈឺហើយ ប្រាប់គាត់ថាបង១អត់ស្រួលខ្លួនសោះ សព្វថ្ងៃ ចាប់បង ហ៊ុយ ហើយ បងហ៊ុយ សមាជិកកន្លែងមន្ទីរហ្នឹង ។

ពីវ៉ន: ហ៊ុយ នៅណា?

ហ៊ុយ: ធ្វើស្រែនៅព្រៃសហ្នឹង

ពីវ៉ន: គេចាប់យកទៅណា?

ហ៊ុយ: ទៅទួលស្លែងហ្នឹង

ហ៊ុយ: ហ្នឹងសុទ្ធតែរឿងយើង គេឆ្លើយដាក់អីហ្នឹង ដល់ហើយខ្ញុំភ័យខ្ញុំទៅអង្គុយខ្ញុំទៅអង្គុយផ្អែក មានទៅនិយាយអីណា និយាយតែមួយមាត់ ឥឡូវរឿងអ្នកណា អ្នកនោះដឹង រឿងធ្វើស្រែ គឺធ្វើស្រែ អ្នកណាធ្វើការនៅអំពេញ ធ្វើការនៅអំពេញ គ្មានរញ៉េរញ៉ៃ ដឹងរឿងនេះ រឿងនោះទេ គ្រាន់តែរឿងប៉ុណ្ណឹងប្រាប់ថាធ្វើស្រែទៅ មិនបាច់ឲ្យនិរសាយកខ្ញុំមកទេ ខ្ញុំភ័យចង់ងាប់ហើយចាប់ខ្ញុំដាក់គុក ប៉ុនខ្ញុំអត់និយាយអញ្ចឹង ប្រាប់គាត់ទេ ប៉ុនខ្ញុំនិយាយខ្លួនឯង អញ្ចឹងខ្ញុំចេះតែបាទ ចេញមកវិញហើយសុំថ្នាំពេទ្យគេមកផឹក ឲ្យនិរសារជូនទៅដល់កន្លែង ។

ពីវ៉ន: ផ្ទះនៅណា?

ហ៊ុយ: នៅជើងឯក

ឃិន: ហៅ ហៅទៅប្រុងរបៀបម៉េច? គេបំពាក់នយោបាយអី?

ហ៊ុយ: អត់មាននិយាយអីទេ គ្រាន់តែនិយាយរឿងហ្នឹង ថារឿងអ្នកណា អ្នកណឹងដឹង អ្នកណាធ្វើស្រែ ធ្វើស្រែ គ្រាន់តែសរសេរសំបុត្របានហើយ មិនបាច់ហៅខ្ញុំទៅសួរទេ អាណឹងគំនិតខ្ញុំនិយាយខ្លួនខ្ញុំទេ ខ្ញុំគិតខ្លួនខ្ញុំ

ពីរីនៈ ហើយពូធ្លាប់ធ្វើខុសពីមុនមកអត់បានគេហៅពូ?

ហ៊ុយៈ មនុស្សវាជាប់នៅហ្នឹងទៀត អ្នកធ្វើការនៅហ្នឹងមានរឿងអីវាចាប់ទាំងអស់ ទួលស្លែងជាប់ចង់អស់ហើយ ចង់ពាយមនុស្សហើយហ្នឹង

ពីរីនៈ ពូធ្វើអីនៅបឹងជើងឯក?

ហ៊ុយៈ ធ្វើស្រែ

ឃិនៈ ៧៨គេឲ្យពូទៅបឹងជើងឯក?

ហ៊ុយៈ ពាក់កណ្ដាកឆ្នាំ៧៨

ពីរីនៈ ចុះពូធ្លាប់ទៅទួលស្លែងទេ?

ហ៊ុយៈ ទួលស្លែងកាលមុនទៅ

ពីរីនៈ ធ្វើអីនៅហ្នឹង?

ហ៊ុយៈ កាលមុននៅកន្លែងមុខទួលស្លែងហ្នឹង ដល់ក្រោយមកទៀតខ្ញុំអត់ទៅទេ

ពីរីនៈ ពូធ្វើអីគេនៅទួលស្លែងហ្នឹង?

ហ៊ុយៈ ខ្ញុំអ្នកចាំទទួលអ្នកទោសអ្នកអី គេឲ្យមុខងារខ្ញុំ ពួកខាងគ្រប់ក្រសួងគេបញ្ជូនមកកន្លែងហ្នឹងគេអត់ឲ្យចូលទៅក្នុងទេ ហើយបានគេកត់ឈ្មោះកត់អី ហើយប្រាប់គេ ប្រាប់ទៅហាអីហ្នឹង យកឈ្មោះឲ្យបងធី គាត់នៅក្នុងសរសេរឈ្មោះហ្នឹងឲ្យទៅ ហា ទៀតហើយបាន ហា សរសេរឈ្មោះហ្នឹងឲ្យទៅ ឌុច

ពីរីនៈ ប៉ុន្មានគទៀតបានទៅដល់ ឌុច?

ហ៊ុយៈ ពីខ្ញុំសរសេរឈ្មោះកត់ឈ្មោះ រាប់ឲ្យដឹងមនុស្ស ហើយបានសរសេរឈ្មោះ ឲ្យទៅបងធី ទាំងមនុស្សទាំងអីទាំងអស់ អត់ឲ្យឡានគេដឹកចូលក្នុងទេ លាក់ការកន្លែងហ្នឹង អត់ឲ្យចូលទេ ចាំទទួលខាងក្រៅនេះ ហើយដល់ពេលចាប់ គេយកពួកខ្ញុំពួក ហា រើសកម្លាំងអីមាឌ ធំៈ ពួកសូរអីហ្នឹង យកទៅជាមួយគេទៅចាប់ៗ

ឃិនៈ ចាប់កន្លែងណា?

ហ៊ុយៈ ចាប់កន្លែងណាដែលមានឈ្មោះឲ្យចាប់

ឃិនៈ មានទៅចាប់ដល់បណ្ដាខេត្តដែរ?

ហ៊ុយៈ ចាស ហ្នឹងក៏ទៅ គេឲ្យឈ្មោះទៅ

ពីរីនៈ ពូភាគច្រើនអ្នកទោសគេយកពីខាងណាមក?

ហ៊ុយៈ ហឺ នៅគ្រប់ទិសទាំងអស់ ខាងបូព៌ា និរតី បច្ចិម នៅអំពេញទាំងអស់

ពីរ៉ែនៈ ហើយដែលឃើញមានគេយកអ្នកទោសស្រីៗចូលទៅក្នុងហ្នឹងទេ?

ហ៊ុយៈ អ្នកទោសស្រីៗក៏ចូលក្នុងហ្នឹងដែរ

ឃិនៈ ដាក់ ដាក់ដោយឡែក?

ហ៊ុយៈ ដោយឡែកពីគ្នា ស្រីដោយខ្លួន ប្រុសដោយខ្លួន

ពីរ៉ែនៈ ពូធ្វើតាំងពីឆ្នាំណាមក?

ហ៊ុយៈ តាំងពី៧៦ ៧៧ ដល់ពាក់កណ្ដាលឆ្នាំ៧៨ បានមកធ្វើស្រែ

ឃិនៈ ខ្ញុំសុំបញ្ជាក់លោកពូបន្តិច ពេលលោកពូនៅក្នុងគុកហ្នឹងមានបានឃើញទារុណកម្មអីខ្លះ?

ហ៊ុយៈ ទារុណកម្មគេអត់ឲ្យយើងទៅទេ ពួកគេអ្នកសួរផ្នែកគេដោយខ្លួន សូម្បីតែហូបបាយក៏មិនជាមួយគ្នាដែរ ក្រុមពួកសួរដោយខ្លួនពួកយាមដោយខ្លួនៗ

ឃិនៈ មានដែលឃើញអ្នកធ្វើទ័ពអីហើយបានរួចខ្លួនដែរទេ?

ហ៊ុយៈ អត់មានទេ

ពីរ៉ែនៈ ពូធ្លាប់ទៅព្រៃសទេ?

ហ៊ុយៈ ព្រៃសក៏ធ្លាប់ទៅ

ពីរ៉ែនៈ ពូទៅឆ្នាំណា?

ហ៊ុយៈ ព្រៃស បើនៅធ្វើការទួលស្លែង ទៅជាមួយគេហើយ

ពីរ៉ែនៈ ទៅជាមួយអ្នកណាខ្លះ?

ហ៊ុយៈ ទៅជាមួយ ហឺ ជាមួយ ផល ជាមួយ ប៉េន

ឃិនៈ ទៅ យ៉ាងម៉េច? ទទួលមនុស្សយ៉ាងម៉េច?

ហ៊ុយៈ បាទ ទទួលមនុស្សពីព្រៃសមក គេដទៅជួយទប់ទឹកអី ក៏ទៅដែរ ទឹកជំនន់អី

ពីរ៉ែនៈ ទៅព្រៃស យកមនុស្សរបៀបម៉េចមកពីណា?

ហ៊ុយៈ មនុស្សដាក់មកទាំងឡានៗហ្នឹង

ពីរ៉ែនៈ ទាំងអស់ខុសអីបានគេយក?

ហ៊ុយៈ មិនដឹងដែរ ព្រោះអារឿងអ្នកដែលមានរឿងគេមិនឲ្យដឹងរឿង ដូចថា តាហ៊ុយ នៅហ្នឹងគាត់ដឹងរឿងគេ គាត់នឹងបញ្ជូនឈ្មោះទៅ ឌុច ហើយ ហើយ ឌុច ប្រាប់ ហ៊ ឲ្យនាំកម្លាំងទៅយកគេមក

ពីរីនៈ បានន័យថា មុនទៅ ហ៊ុយ បញ្ជូនឈ្មោះទៅឲ្យ ឌុច សិន?

ហ៊ុយ ហើយបានឲ្យ ហ៊ ទៅហៅពួកខ្ញុំបើកឡានមកដឹក

ឃិនៈ ខ្ញុំចង់ដឹងគុក២ហ្នឹង គុកព្រៃស ហើយគុកទួលស្លែង គុកមួយណាធ្ងន់ជាង?

ហ៊ុយៈ ព្រៃស អត់មានគុកទេ កន្លែងធ្វើស្រែហ្នឹង ធ្វើស្រែធម្មតា តាមអង្គភាព ដល់អ្នកណា មានរឿង គេយក

ឃិនៈៈ យកពីណាពីណីឲ្យធ្វើស្រែនៅព្រៃសហ្នឹងសិន ហើយធ្វើបានមិនបានតាមផែនការ គេ បញ្ជូនឈ្មោះមកទួលស្លែង អញ្ចឹងមិនមែនជាគុកសន្តិសុខទេ?

ហ៊ុយៈ បាទ

ពីរីនៈ អ្នកទៅព្រៃសភាគច្រើនជាមនុស្សរបៀបម៉េច?

ហ៊ុយៈ គ្រប់ក្រសួង គ្រប់កន្លែងទាំងអស់

ពីរីនៈ មាននារីៗនៅព្រៃសទេ?

ហ៊ុយៈ មាន

ពីរីនៈ ប៉ុន្មានដែរ?

ហ៊ុយៈ រាប់ច្រើនគ្នា តិចណាស់ ក៏៤-៥០០នាក់ដែរ

ពីរីនៈ ពីណាគេអ្នកដឹកនាំនារីៗនៅព្រៃស?

ហ៊ុយៈ អត់ស្គាល់ផង វាសុទ្ធតែអ្នកមាន???ដូចតែគ្នា គ្រាន់ថាគេទុកចិត្តអ្នកណា អ្នកនោះ កាន់កាប់

ពីរីនៈ ចុះមនុស្សរបៀបម៉េចដែលគេបញ្ជូនទៅព្រៃស?

ហ៊ុយៈ អ្នកដែលខុស មិនទាន់អាចចាប់ដាក់គុកបាន គេឲ្យទៅធ្វើស្រែសិន បើមានសកម្មភាព អីខុស គេចាំយកចំណុចយើង គេយកដាក់គុកហើយ

ពីរីនៈ ពូនៅព្រៃស ដែលស្គាល់ មាស ប៉េងគ្រី ដែរទេ?

ហ៊ុយៈ មាស ប៉េងគ្រី នៅកំពង់ស្វាយ លើសាលាស្រុកកោះធំ

ពីរីនៈ គាត់ធ្វើអីនៅព្រៃស ?

ហ៊ុយៈ គាត់បើកឡាន

ពីវិនៈ ឡានដឹកអីគេ?

ហ៊ុយៈ ឡានដឹកអីៗ នៅព្រៃស

ពីវិនៈ ប៉េន គ្រី ដែលដឹកអ្នកទោសដែរអត់?

ហ៊ុយៈ មុនដឹកអ្នកទោស

ពីវិនៈ ដឹកពីណាទៅណា?

ហ៊ុយៈ មុននៅភ្នំពេញ ដឹកយកមកជើងឯក ជើងអី

ពីវិនៈ ចុះគាត់ដែរទៅទួលស្លែងដែរ?

ហ៊ុយៈ អត់ដែលទៅទេ តាំងពីដកពីទួលស្លែងមកលែងទៅហើយ

ពីវិនៈ បានន័យថា គាត់ធ្លាប់នៅទួលស្លែង?

ហ៊ុយៈ មុនធ្លាប់នៅទួលស្លែង?

ពីវិនៈ គាត់នៅធ្វើអីនៅទួលស្លែង ?

ហ៊ុយៈ ជាងឡាន បើកបរឡាន

មករាៈ គាត់នៅក្នុងឆ្នាំណា?

ហ៊ុយៈ មិនដឹងឆ្នាំប៉ុន្មាន.

មករាៈ ចុះឆ្នាំណាគាត់ចេញទៅ?

ហ៊ុយៈ ភ្លេចហើយ

ពីវិនៈ ពូ ចុះ ហ៊ុយ នៅព្រៃសម៉េចដែរ?ដឹកនាំ គ្រប់គ្រងមនុស្សនៅព្រៃសទាំងមូលហ្នឹង?

ហ៊ុយៈ គ្រប់គ្រងទាំងអស់

ពីវិនៈ ទាំងយុទ្ធជន ហើយយុទ្ធនារី ទាំងអស់ប៉ុន្មាននាក់?

ហ៊ុយៈ គ្នាទាំងអស់ តិចណាស់៥០០នាក់ឡើង

ពីវិនៈ ចុះយុទ្ធជន ?

ហ៊ុយៈ មិនដឹងប៉ុន្មានៗដែរ?

ពីវិនៈ ប្រពន្ធគាត់ឈ្មោះអី?

ហ៊ុយៈ ខ្ញុំមិនស្គាល់ឈ្មោះទេ

ពីវិនៈ ចុះអនុប្រធាននៅព្រៃសឈ្មោះអី?

ហ៊ុយៈ គ្មានទេ មានតែគាត់មួយហ្នឹង

ពីរីនៈ ពីណាគេនៅក្រោមគាត់.?

ហ៊ុយៈ ក្រោមគាត់មានតែ ជំនួសឲ្យ ជំនួយការឲ្យ ហ៊ុយ ក្រោយមកគេចាប់គាត់ដាក់គុកទៅ

ពីរីនៈ ដាក់គុកណា?

ហ៊ុយៈ គុកទួលស្លែង

ពីរីនៈ ពូដឹងថាហេតុអីបានគេចាប់គាត់ដាក់គុក?

ហ៊ុយៈ អត់ដឹងទេ រឿងអញ្ចឹង

ពីរីនៈ ចាប់មុន ហ៊ុយ ចាប់ក្រោយ ហ៊ុយ

ហ៊ុយៈ ចាប់ មុនទៀត

ពីរីនៈ សុំទោសពូការនៅឆ្នាំណា?

ហ៊ុយៈ ខ្ញុំនៅឆ្នាំ៨១

ពីរីនៈ ពូអត់មានការនៅក្នុងសម័យនោះទេ?

ហ៊ុយៈ បាទសម័យហ្នឹង

ពីរីនៈ អត់ទេ នៅក្នុងសម័យ ប៉ុល ពត?

ហ៊ុយៈ ខ្ញុំអត់យកទេ

ពីរីនៈ ម៉េចអញ្ចឹង?

ហ៊ុយៈ ខ្ញុំតែម៉ែឪខ្ញុំមិនរៀបចំ មិនពេញចិត្ត ខ្ញុំអត់យកទេ ហើយគេឲ្យខ្ញុំយកគ្រួសារដែរ តែខ្ញុំថាបើកាន់??? ២ទៀតខ្ញុំឆាប់ផាប់ហើយ អ្នកដែលធ្វើការជាមួយគ្នាហ្នឹង គ្នានៅអត់បានប៉ុន្មានផង គ្នាផាប់ដែរ ។

ពីរីនៈ ម៉េចបានគេយកទៅសម្លាប់?

ហ៊ុយៈ អាណឹងពិបាកដែរ បើយើងប្ដីមានរឿងក្នុងខ្សែរបស់យើង គេចាប់ទាំងប្ដី ទាំងប្រពន្ធ បើប្រពន្ធមានខ្សែខាងប្រពន្ធ ចាប់ទាំងប្ដីទៀត អញ្ចឹងបានខ្ញុំមិនយក

ពីរីនៈ គេធ្លាប់ប្រាប់ពូឲ្យកាដែរតើ?

ហ៊ុយៈ គេសួរខ្ញុំ ចង់បានគ្រួសារអត់? ខ្ញុំថាអត់ទាន់ចង់បានទេ ព្រោះខ្ញុំឃើញអញ្ចឹងហើយ

ពីរីនៈ អញ្ចឹងពូបដិសេធអញ្ចឹងអត់ទាន់ដាក់ទោសអីទេ?

ហ៊ុយៈ អត់ទាន់ដាក់ទោសអីទេ បើយើងនិយាយវាល្អដែរ កុំថាយកអញ្ចេះអញ្ចោះ គេចោទយើងដែរ

ពីវីនៈ ពូ ខ្ញុំនៅអត់ទាន់អស់ចិត្តរឿង ហ៊ុយ ទេ ហេតុអីបានគេបញ្ជូនទៅ?

ហ៊ុយៈ គេចាប់ពីព្រៃសមក

ពីវីនៈ ចាសគាត់ខុសអី?

ហ៊ុយៈ ខ្ញុំអត់ដឹងទេ បង ហ៊ុយ កាលមុន គាត់ប្រាប់ខ្ញុំរឿងធ្វើឡានធ្វើអីខាងបូព៌ា គាត់ធ្លាប់រាប់អានខាងកងពលបូព៌ា បែបមានចម្លើយឆ្លើយដាក់រឿងគាត់ បានគេចាប់គាត់

ពីវីនៈ ឆ្លើយដាក់រឿងអី?

ហ៊ុយៈ មិនដឹងឆ្លើយដាក់រឿងអីៗទេ

ពីវីនៈ ពូធ្លាប់ឃើញ ហ៊ុយ ទាក់ទងជាមួយអ្នកណាខ្លះ?

ហ៊ុយៈ ខ្ញុំអត់ដែលឃើញគាត់ទេ ប៉ុនគាត់និយាយប្រាប់ខ្ញុំ ឡានអីខូចយកទៅខាងបូព៌ា

ពីវីនៈ គាតជួបពូនៅពេលណា និយាយប្រាប់ពូ?

ហ៊ុយៈ នៅក្នុងឆ្នាំ៧៨ ជិតអី

ពីវីនៈ ពេលពូទៅព្រៃស ឬម៉េច?

ហ៊ុយៈ ឡើងមកអំពេញហ្នឹង

ពីវីនៈ ឡើងមកទួលស្លែង?

ហ៊ុយៈ បាទ

ពីវីនៈ ចុះប្រពន្ធគាត់ចាប់មកដែរឬម៉េច?

ហ៊ុយៈ ចាប់ទាំងអស់ ទាំងប្អូនគាត់

ពីវីនៈ ប្អូនគាត់ឈ្មោះអី ?

ហ៊ុយៈ ហឿន

ពីវីនៈ ស្រី ឬប្រុស ហឿន ហ្នឹង?

ហ៊ុយៈ ប្រុស

ពីវីនៈ ប្អូនគាត់នៅព្រៃសធ្វើអីដែរ?

ហ៊ុយៈ ប្អូនគាត់សួរចម្លើយនៅទួលស្លែង

ពីវីនៈ ហឿន ហ្នឹងនៅសួរចម្លើយទួលស្លែង?

ហ៊ុយៈ បាទ ដល់ហើយគេដកមកឲ្យធ្វើស្រែជាមួយ ហ៊ុយ ធ្វើស្រែដល់ហើយ គេចាប់ទាំងអស់បណ្តោយ

ពីរ៉ន: ពូមានដឹងថាគាត់មានបងប្អូនប៉ុន្មាននាក់ពូ?

ហ៊ុយ: អត់ដឹងទេ ស្គាល់តែមួយហ្នឹង

ពីរ៉ន: ក្រោយ៧៩ ពូទៅណាវិញ?

ហ៊ុយ: មានទៅណា បែកហើយនៅតែផ្ទះ

ពីរ៉ន: ពេលវៀតណាមចូល?

ហ៊ុយ: ពេលវៀតណាមចូល កាលហ្នឹងអាពេលបែកហ្នឹងគេបញ្ជូន អាពួក ឌុច មកប្រមូលពួកខ្ញុំពីជើងឯក នឹងទៅទាំងអស់ ពីព្រៃសទៅទាំងអស់ ចូលព្រៃហ្នឹង ហើយគេឲ្យរៀបចំកម្លាំងយុទ្ធជនៗ យុទ្ធនារី ហើយគេបើកាំភ្លើងឲ្យកាន់គ្រប់ដៃ ហើយវាយចុះវាយឡើង ពួកខ្ញុំនាំគ្នារត់ចូលព្រៃ អស់ពីចូលព្រៃ រត់មកផ្ទះហ្នឹង

ពីរ៉ន: នារីនៅព្រៃស គេឲ្យកាន់កាំភ្លើងអីវាយជាមួយដែរ?

ហ៊ុយ: អូនារីអត់ទេ គេបញ្ជូនឲ្យនៅតាមសហករណ៍ភូមិភាគពាយព្យ គេយកផ្ញើរ ហើយដល់នារីអស់ហ្នឹង វាពិបាកយាមកាត់ផ្លូវ ដាក់កម្លាំងយាមឥពួកខ្ញុំឃើញ ឲ្យទៅជួយដោះថាពិបាកថាគេចេះតែចង់រំលោភអីហ្នឹង ឲ្យយាមចាំឃើញពួកខ្ញុំឲ្យមកជួយរំដោះយកនារីពីអន្តរាពមកវិញ ដល់ហើយពួកខ្ញុំនាំគ្នាជួប ទៅកន្លែងនារីសុំអង្វរចង់សាប់សុំឲ្យជួយដោះស្រាយយកមក ខូចៗណាស់ សុទ្ធតែរកចាប់រករហូត គ្មានអ្នកណាស្អាតៗទេ។ ពួកខ្ញុំមាននីអី អះអាងបណ្តោយថា សុំយកទៅរៀបចំកម្លាំងកងទ័ពវិញ។

ពីរ៉ន: អះអាងយ៉ាងម៉េច?

ហ៊ុយ: និយាយពួកខ្ញុំហ្នឹង ទៅជាមួយគ្នា ទៅហើយសហករណ៍ពួកឈ្លប សុំពីពួកហ្នឹងមកវិញ សុំថាយកមករៀបចំកម្លាំងទ័ពអីវិញមក អញ្ចឹងបានបាន បើមិនធ្វើអញ្ចឹងអត់បានទេ ដល់បានអញ្ចឹងមកភ័យទៀត នារីអស់ហ្នឹងសប្បាយណាស់តាមផ្លូវរហូត ខ្ញុំថាកុំសប្បាយណា គា ឌុច មិនដឹងយ៉ាងម៉េចទៀត មិនស្រួលគា ឌុច រករឿងទៀត ដល់ហើយខ្ញុំថាចាំមើលម៉េចៗកុនហើយ ទៅដល់ហ្នឹង ដល់ហើយ មកដល់អត់អីដែរ អត់ហានឡូឡាដែរ ហើយអញ្ចឹងក៏ស្ងាត់ទាំងអស់ទៅ នារីនៅដោយនារី ពួកខ្ញុំនៅដោយពួកខ្ញុំទៅ។

ពីរ៉ន: ចុះពូ ឈ្មោះដែលពូធ្លាប់ជួយសង្គ្រោះហ្នឹង?

ហ៊ុយ: ភ្លេចអស់ហើយយូរឆ្នាំហើយ

ពីរីនៈ ហើយដល់ពេលយកមក យកមកណាវិញ?

ហ៊ុយៈ យកមកតាមកម្លាំងអន្តភាពរបស់ខ្ញុំទាំងអស់

ពីរីនៈ ប៉ុន្មាននាក់ដែលពូហៅមកវិញបាន?

ហ៊ុយៈ ចូល៣០-៤០នាក់ ដល់ហើយចូលព្រៃ ខ្ញុំក៏បាក់បែក គេក៏បាក់បែកយកប្រះអាយុ គ្រប់គ្នា

ពីរីនៈ ពូ ឌុច ប្រធានមន្ទីរទួលស្លែងតាំងពីឆ្នាំណាមកពូ?

ហ៊ុយៈ ទេ តាំងពីខ្ញុំឃើញមក មិនដឹងតាំងពីណាទេ តាមគេនិយាយតាំងពីណា ពីណីមក

ពីរីនៈ ដំបូង ឌុច មកពីណាមកវិញ?

ហ៊ុយៈ គេថាមកពីបច្ចិម

ពីរីនៈ ស្រុកកំណើតនៅណាមានដឹងទេ?

ហ៊ុយៈ ស្រុកកំណើតនៅកំពង់ធំ

ពីរីនៈ ពូនៅព្រៃស ពូអាចស្គាល់នារីៗណាខ្លះនៅព្រៃស ពូអាចចាំឈ្មោះបានទេ?

ហ៊ុយៈ លែងចាំហើយ

ពីរីនៈ ចុះពូ ពូថា ហ៊ុយ ប្រុងឲ្យប្អូនគាត់រៀបការជាមួយពីណាគេឈ្មោះ សារី នៅ នៅ ព្រៃស ពូដែលស្គាល់ទេ?

ហ៊ុយៈ អត់ដឹងដែរ

ពីរីនៈ ចុះនៅព្រៃសពូឃើញនារីហើយបុរស អាចនិយាយរកគ្នាបានទេ?

ហ៊ុយៈ និយាយគ្នាធម្មតា មានអី គ្រាន់ថាវានៅកន្លែងវាខុសៗគ្នា

ពីរីនៈ ពូនៅព្រៃសគេមានដែលរៀបការរៀបអីទេ?

ហ៊ុយៈ អត់មានទេ

ពីរីនៈ អញ្ចឹងពូដកចេញពីព្រៃស មកទួលស្លែង?

ហ៊ុយៈ បាទ ពេលទឹកជំនន់គេឲ្យមកពីទួលស្លែងមកជួយទប់

ពីរីនៈ ដល់ពេលហើយ គេដកទៅជើងឯក

ហ៊ុយៈ បាទដក

ហ៊ុយៈ បាទក្រោយមកបានដកពីទួលស្លែងមកជើងឯកវិញ

ពីរីនៈ ពូនៅជើងឯកធ្វើអី?

ហ៊ុយៈ ធ្វើស្រែ

ពីរីនៈ ក្រៅពីធ្វើស្រែ ធ្វើអីទៀតនៅហ្នឹង?

ហ៊ុយៈ ខ្ញុំប្រធានកងធ្វើស្រែនៅហ្នឹងប្រមាណ៣ក្រុម

ឃិនៈ នៅជើងឯកមានរណ្តៅសម្លាប់មនុស្ស ពេលដែលសម្លាប់ក្រុមអ្នកអ្នកសម្លាប់ ឬពីទួលស្លែង?

ហ៊ុយៈ ក្រុមពីទួលស្លែង អត់ទេក្រុមហ្នឹងគេយកតាំងពីទួលស្លែងមក

ឃិនៈ កាលណាគេដឹកមនុស្សគេយកក្រុមហ្នឹងទៅហ្នង?

ហ៊ុយៈ ក្រុមគេនៅយាមនៅហ្នឹងហ្នង

ឃិនៈ ក្រុមប្អូនឯងអត់មានដៃដល់អីទេ?

ហ៊ុយៈ អត់ទេ ដៃដល់បានត្រឹមតែបញ្ជូន ជួយដឹកជញ្ជូនជួយបណ្តើរទៅឲ្យគេ

ឃិនៈ បណ្តើរពីណាទៅណា?

ហ៊ុយៈ បណ្តើរពីផ្ទះទៅរណ្តៅហ្នឹង

ឃិនៈ ទៅដល់មានផ្ទះមួយអញ្ចឹង ហើយជួយយាមជយអីគេអញ្ចឹង?

ហ៊ុយៈ បាទ

ឃិន ដែលឲ្យថាជួយវាយជួយអីអត់ទេ?

ហ៊ុយៈ អត់ទេ តែពួកគេនៅហ្នឹង គេធ្វើមួយក្រុមគេ

ឃិនៈ មានដែលឃើញជនជាតិបរទេសអីទេ?

ហ៊ុយៈ អត់ទេ ឃើញតែខ្មែរ

ពីរីនៈ ចុះពូគេអត់មានថាឲ្យពូ វាយមនុស្សអញ្ចេះដែរអីអត់ទេ?

ហ៊ុយៈ ចាំមើលតា ឌុច ពេលវាយម្តងៗ តាឌុច តាហ៊ី

ឃិនៈ មេធំទៅដែរ?

ហ៊ុយៈ បាទ

ពីរីនៈ វាយខ្លួនឯងឬម៉េច?

ហ៊ុយៈ អត់វាយទេ ទៅអង្គុយមើល

ឃិនៈ វាយចប់បានមកវិញ?

ហ៊ុយៈ បាទ

ពីរីនៈ ចុះពីណាគេអ្នកវាយ?

ហ៊ុយៈ មួយក្រុមគេនៅហ្នឹង ក្រុមរបស់ គេង

ពីវ័នៈ ចុះពូឮថាប្អូនថ្ងៃឌុច អីគេវាយចោលនៅហ្នឹងដែរ?

ហ៊ុយៈ អញ្ចឹងបានថា ប្អូនថ្ងៃឌុច ២នាក់ក៏ចាប់ដាក់គុកទទួលស្វែងដែរ

ឃិនៈ ក្រោយមកយកទៅណា?

ហ៊ុយៈ យកទៅសម្លាប់ដែរ

ឃិនៈ អ្នកណាអ្នកបញ្ជារ?

ហ៊ុយៈ មានតែឌុច ហ្នឹង

ពីវ័នៈ ពូដឹងទេ ហេតុអីបានគេសម្លាប់ប្អូនថ្ងៃគាត់?

ហ៊ុយៈ អត់ដឹង អញ្ចឹងបានខ្លាចអញ្ចឹងខ្លាំងជាងគេ ប្អូនគេ គេសម្លាប់ ចុះទម្រាំតែពួកខ្ញុំ គេធ្វើម៉េចទៀត គេសម្លាប់ចោលអស់ គេគ្មានទុកទេ ។

ពីវ័នៈ អញ្ចឹងគេអត់មានគម្រាមពូទេថា ឲ្យពូជួយវាយអ្នកនេះអ្នកនោះអីអត់ទេ?

ហ៊ុយៈ ឲ្យខ្ញុំទៅ មុនដំបូងខ្ញុំកត់ឈ្មោះ រាល់ដងខ្ញុំកត់ឈ្មោះ ព្រោះខ្លាចបាត់ ដល់ថ្ងៃ១ តាឌុចឲ្យហៅខ្ញុំទៅ ឲ្យពួកអ្នកវាយមកហៅខ្ញុំទៅ ថា ហ៊ានវាយមនុស្សអត់ ដាច់ខាតឬមិនដាច់ខាត? ដាច់ខាបង ចុះបើគេថាដាច់ខាតយើងមិនដាច់ខាត បើមិនដាច់ខាត មានតែយើងងាប់ ដាច់ខាតអញ្ចឹងអ្ហែងវាយមួយមើល យកដែកពីគេមកដាក់មួយទៅ ដាក់មួយបោះដែកចោលឲ្យគេទៅព្រោះមុខងារខ្ញុំអ្នកកត់ឈ្មោះ បើបាត់ឈ្មោះគេរឿងទៀត វាយហើយក៏គេឲ្យអាអ្នកវាយរាប់ឲ្យគ្រប់ដែរ ហើយអ្នកកត់ហ្នឹងរាប់ឲ្យគ្រប់ដែរ តែបាត់ត្រូវតែមានទោសដែរ ។

ឃិនៈ ដាក់ឲ្យគេមើលមួយសិន

ហ៊ុយៈ បាទ

ពីវ័នៈ ចុះបើពូអត់ព្រមធ្វើតាមគេ?

ហ៊ុយៈ ជាប់គុកហើយអត់រស់ទេ ហើយមិនមែនងាប់តែយើងម្នាក់ឯងទេ សូម្បីតែម៉ែឪបងប្អូនក៏ងាប់ដែរ គ្មានរស់ទេ រឿងហ្នឹងវាអញ្ចឹង វាពិបាកអញ្ចឹងហ្នង

ពីវ័នៈ ចុះកាលហ្នឹងបងប្អូនពូនៅណាដែរ?

ហ៊ុយៈ បងប្អូននៅភូមិ នៅស្រុក គេផ្លាស់អត់ឲ្យនៅទៀត គេផ្លាស់នៅភូមិដើងទៀត គេថាផ្ទះហ្នឹងមានកម្មសិទ្ធិ កាលហ្នឹងផ្ទះ២ ផ្ទះ១ប៉ុនណឹង នៅពីក្រោយ ហើយអានៅមុខគេទុកឲ្យធ្វើមណ្ឌលកុមារនៅហ្នឹង ហើយប្អូនខ្ញុំមួយខ្ញុំយកទៅ កលហ្នឹងខ្ញុំមកដោះគេជាមួយតាម៉ុន មកធ្វើជាមួយតាហ៊ុយ មកធ្វើនៅព្រៃសហ្នឹង តាម៉ុនមកដោះពួកកងហា

អ្នកធ្វើស្រែរត់មកផ្ទះ ហើយកងហាត្ថា៦នាក់មកតាមហើយមានបានឃើញ ពួកអស់ហ្នឹងណា មកដល់អាកន្ទែងទី១៥គេហ្នឹង គេចាប់ដាក់គុកនៅហ្នឹង ដល់ហើយ ឌុចហ្នឹងរាយការណ៍ឡើងទៅលើឲ្យមកដោះ តាឌុចឲ្យតាម៉ុន ហើយតាម៉ុនហៅខ្ញុំទៅមកជាមួយគ្នា ឲ្យមកជួយដោះពួកហ្នឹង ពួកខ្ញុំមកការពារគាត់ទៅ មកដោះពួកហ្នឹង ក៏ទទួលផ្ទះខ្ញុំក្បែរហ្នឹងដែរ ខ្ញុំសុំតាម៉ុន មកលេងផ្ទះខ្ញុំ ដល់ឃើញប្អូនខ្ញុំកើតខានលឿង ហើយពេទ្យគេអត់មើលទេតឹងតែងហើយ ម៉្លោះហើយទៅវិញខ្ញុំសុំបង ហ៊ា អនុប្រធានទួលស្លែងហ្នឹងថា បង១ប្អូនខ្ញុំកើតខាន់លឿង ខ្ញុំសុំបងឯងមកឲ្យពេទ្យចាក់ថ្នាំ ហើយខ្ញុំក៏និយាយជាមួយពេទ្យបានអស់ហើយ ហើយគាត់ថាអញ្ជើងអ្ហែងទៅយកមក ។ ថ្ងៃក្រោយខ្ញុំទៅយក មកយកទៅចាក់ថ្នាំបានប៉ុន្មានមួយអាទិត្យ ២អាទិត្យវិញជា ហើយសុំតាហ៊ា យកមកផ្ទះវិញ គាត់អត់ឲ្យ អត់ឲ្យមកវិញ ធ្វើម៉េចបេះ គាត់ថាអត់ឲ្យទៅផ្ទះទេ ទុកវានៅហ្នឹង អ្ហែងទៅផ្ទះបានកម្លាំងឯណាយាម ឲ្យវានៅយាមនឹងគេ នៅ១យាមរហូតដល់បែកហ្នឹង ចូលព្រៃទៅព្រៃ ដល់ខ្ញុំរត់មកនេះមក តាឌុច សម្លាប់ប្អូនខ្ញុំចោលជាមួយតាហ៊ា ។

ពីរីនៈ សម្លាប់ប្អូនចោលទៀត?

ហ៊ុយៈ សម្លាប់ប្អូនខ្ញុំ តាហ៊ា ទាំងប្រពន្ធអីហ្នឹងចោល ។ តាហ៊ា ក៏តាឌុចហ្នឹងសម្លាប់ ហើយប្អូនខ្ញុំហើយប្រពន្ធហ៊ា ក៏ឌុចជាអ្នកសម្លាប់

ពីរីនៈ ចុះ ហ៊ា រាល់ថ្ងៃ នៅរស់ ឬស្លាប់?

ហ៊ុយៈ ស្លាប់អស់ហើយ

ពីរីនៈ គាត់សម្លាប់នៅណា?

ហ៊ុយៈ គាត់ស្លាប់នៅអីព្រៃ

ពីរីនៈ ប្អូនពូស្រី ប្រុសពូ?

ហ៊ុយៈ ប្រុស ដល់ខ្ញុំរត់មកវិញថាខ្ញុំចូលដៃដើងនេះ ប្អូននោះសម្លាប់ចោល គេឲ្យកម្លាំងតាមមកបាញ់ពួកខ្ញុំទៀត ខ្ញុំបេះតែរឹងមក មកដល់ពាក់កណ្តាលផ្លូវឈើតាមផ្លូវរហូតទៀត ខ្ញុំបោះអីចោលអស់ ដើរខ្លួនទទេ តែខោបាំដិបមួយ អាវ១ មានតែប៉ុណ្ណឹងទេ មកផ្ទះវិញ ។

ពីរីនៈ ពូមានដឹងថាប្អូនពូ ខុសអីបានគេសម្លាប់ចោល?

ហ៊ុយៈ ព្រោះខ្ញុំដឹងថាខ្ញុំរត់មកនេះហើយ គេចោទថាខ្ញុំចូលខាងនេះហាស គេសម្លាប់ពួកហ្នឹងចោល

ពីរីនៈ គេដឹងថាប្អូនដែរ?

ហ៊ុយៈ បាទ

ពីរីនៈ កាលពូនៅទួលស្លែងប្អូនពូធ្វើនៅហ្នឹងដែរ?

ហ៊ុយៈ បាទ

ពីរីនៈ ប្អូនពូឈ្មោះអីទៅ?

ហ៊ុយៈ ម៉េង

ពីរីនៈ ត្រកូលអីពូ

ហ៊ុយៈ គីម ឡឹងម៉េង

ពីរីនៈ គេសង្ស័យថាប្អូនពូៗ ចុះម៉ែឪពូនៅណាទៅ?

ហ៊ុយៈ ម៉ែឪខ្ញុំនៅខាងភូមិពោធិបាន

ពីរីនៈ នៅធ្វើស្រែធ្វើអីហ្នឹងទេ

ហ៊ុយៈ បាទ

ពីរីនៈ ពូមានកូនប៉ុន្មាននាក់ហើយ?

ហ៊ុយៈ ខ្ញុំ៩នាក់

ពីរីនៈ ហើយកូនបងអាយុប៉ុន្មានហើយពូ?

ហ៊ុយៈ អាយុ២១ឆ្នាំ

ពីរីនៈ ប្អូនខ្ញុំ១ឆ្នាំ ស្រីប៉ុន្មាន?

ហ៊ុយៈ ស្រី៣នាក់ ប្រុស៦នាក់

ពីរីនៈ ទូចម៉េញពៅគេ?

ហ៊ុយៈ បាទពៅគេ

យិនៈ ប្អូនយល់យ៉ាងណាដែរចំពោះរបបអឌិតកាលដែលធ្លាប់បានបម្រើមួយរយៈកន្លងមក?

ហ៊ុយៈ អញ្ចឹងបានខ្ញុំនិយាយ ទៅវាល់ដងនិយាយថារឿងអីក៏ដោយមិនសមឲ្យពួកខ្ញុំខុស មិនមែនស្ម័គ្រទឹកចិត្ត ដូចឥឡូវ សុំដាក់ដីម៉ង់ ដាក់លុយ ដាក់កាក់អីសុំចូល អត់មានអញ្ចឹងទេ គេគៀរយកទៅបណ្តោយ ចេញវិញ ចេញអត់រួច ចេញទៅណា ចេញមានតែរត់ចោលស្រុកខ្មែរ ចេញវាអត់ផុត បើយកម៉ែឪទៅវារត់ រួចខ្លួនយើង

ក៏ម៉ែឪយើងស្លាប់ដែរ អញ្ចឹងរឿងអីក៏ដោយ????ខ្ញុំបម្រុងសម្លាប់ខ្លួនឯងម្តង ហើយ ខ្ញុំយកកាំភ្លើងប្រុងបាញ់ខ្លួនឯង ខ្ញុំយំចង់ងាប់ហើយម៉ោង១២យប់ខ្ញុំនៅទួលស្លែង គាហ៊ស្តីឲ្យខ្ញុំ ខ្ញុំលើកកាំភ្លើងបើកសោរហើយបម្រុងបាញ់ខ្លួនឯង បាញ់ខ្លួនឯងសម្លាប់ហើយមើលទៅ ចុះខ្ញុំព្រាប ទន្សាយ ៣ ជៀម ៣ពែ ថ្វាន់ នៅលើគ្រប់គ្រងទាំងអស់ ងាប់កូនទាគេអស់២០ គេចោទខ្ញុំពេញទឹក ពេញដី គេដៀលខ្ញុំ ខ្ញុំយំទាំងយប់ បម្រុងបាញ់ខ្លួនឯង នឹកឃើញអាណិតម៉ែឪ បើបាញ់ខ្លួនឯងងាប់ហើយតែម៉ែឪជៀសមិនផុត ព្រោះយើងមិនដឹងមានគម្រោងការណ៍អី គេចោទយើងអញ្ចឹង

ពីរីនៈ ពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ហ៊ុយៈ ខ្ញុំបងប្អូន៧នាក់

ពីរីនៈ អញ្ចឹងដែលប្អូនពូ ឌុច សម្លាប់ចោលប្អូនទីប៉ុន្មាន?

ហ៊ុយៈ ប្អូនទី២ ៣ទាំងខ្ញុំ

ពីរីនៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហ៊ុយៈ ស្រី១ ប្រុស៦នាក់

ពីរីនៈ ពូកូនទីប៉ុន្មាន?

ហ៊ុយៈ ខ្ញុំបងគេបំផុត

ពីរីនៈ ពូខ្ញុំអរគុណច្រើន

ហ៊ុយៈ ១០ខែ មិនមែន១០ឆ្នាំទេ

ឃិនៈ ១០ខែ?

ពីរីនៈ ពូអាចនិយាយរឿងហ្នឹងបន្តិចបានទេ?

ហ៊ុយៈ គេចោទថាខ្ញុំប្រធានអ្នកយាមគុកនៅទួលស្លែង

ឃិនៈ ដាក់នៅណា? ខេត្តកណ្តាលឬអី?

ហ៊ុយៈ គេប្រើឲ្យធ្វើស្រែនៅព្រំដែន

ឃិនៈ ធ្វើស្រែដែរ?

ហ៊ុយៈ បាទ ធ្វើស្រែនៅជាប់នេះប្រហែលប៉ុន្មានខែ ជាង១ខែ ហើយបានគេឲ្យទៅធ្វើស្រែនោះៗ

ឃិនៈ ច្រើនគ្នាទេ?

ហ៊ុយៈ គ្នាប្រហែលជាង១០នាក់

ឃិនៈ ធ្វើឲ្យអន្តរាយពណា បម្រើខាងណា?

ហ៊ុយៈ បញ្ជូនឲ្យខាងស្រុក ចេះតែធ្វើ តែនៅស្តាយខ្លួនដែរ មិននឹកថាខ្លួនឯងមកនៅកន្លែងហ្នឹង កុំតែសង្គ្រាមកើត កុំតែតាហិ ហៅខ្ញុំទៅ ក៏មិនបានទៅហ្នឹង សួរទៅភស្តុតាងនៅតាហិ ខ្ញុំថាឲ្យមុខគេមុខឯងគ្រប់គ្នាកុំតែបងឯងឲ្យខ្ញុំទៅហ្នឹង បងឯងថាឲ្យខ្ញុំទៅអាមេរិន ព្រោះខ្ញុំទៅអាមេរិនទៅច្បាំង កន្លែងទួលស្លែង សុន សេន មកប្រជុំហ្នឹង ខ្ញុំឃើញកន្លែងហ្នឹងពិបាក ខ្ញុំឡើងឈរសុំហ្នង។

ឃិនៈ មុខ សុន សេន ហ្នឹង?

ហ៊ុយៈ បាទមុខ សុន សេន ហ្នង ឈរសុំហើយមនុស្សនៅរៀនសូត្រនឹងច្រើន សុំ អុំៗ ខ្ញុំសុំអុំឯងទៅទ័ពវិញហើយ។ មិត្តឯងហានវាយយួនអត់? ខ្ញុំថាហាន អុំហាន។ តាមពិតគឺខ្ញុំទៅនោះឆាប់ក៏ឆាប់ រស់ក៏បានយូរដែរ នៅកន្លែងនេះរស់តិចណាស់ ឃើញតែបាត់ៗគ្នារហូត ហើយកងរយ សុទ្ធតែកងរយគ្នាពីមុនមក ហើយធ្វើការហ្នឹង ចាប់ដាក់គុក សម្លាប់បន្តគ្នា អញ្ចឹងបានខ្ញុំខ្លាច ណាស់ ខ្ញុំឡើងសុំ ខ្លាចដឹងរឿងកន្លែងហ្នឹង ខ្លាចទៅច្បាំងជាមួយវៀតណាម ហើយវៀតណាមចាប់បានអីទៅដឹងឫងកន្លែងនេះ

ពីរ៉ែនៈ ពូអាចនិយាយប្រាប់ខ្ញុំថាពូដាប់ គេចាប់អីយកទៅដាក់នៅណា?

ហ៊ុយៈ ចាប់ពីឃុំគេហៅពីផ្ទះទៅ ខ្ញុំទើបតែបានកូន១ ប្រពន្ធពោះធំ

ពីរ៉ែនៈ មន្ទីរឃុំគេមកហៅទៅ?

ហ៊ុយៈ មន្ទីរឃុំមកហៅទៅ ប៉ុនមន្ទីរស្រុក ខាងនគរបាលគេមកហៅទៅ មកហៅទៅស្រួលបួលមានអី មកហៅទៅសម្ភុតដែរ

ពីរ៉ែនៈ គេដាក់គុកអីនៅណា?

ហ៊ុយៈ គុកនៅកោះអំ ខ្ញុំចេះតែទៅ ទៅដល់នោះ គេចោទខ្ញុំថាប្រធានអ្នកយាមគុក

ឃិនៈ គេយកទៅដាក់ហ្នឹងមានសួរចម្លើយអីដែរទេ?

ហ៊ុយៈ គេកត់ត្រា

ឃិនៈ ខ្មែរវៀតណាម?

ហ៊ុយៈ ខ្មែរយើង

ឃិនៈ ប៉ុនគេមិនប្រើទារុណកម្មអីទេ?

ហ៊ុយៈ អត់ទេ បើប្រើទារុណកម្មឲ្យបាញ់ខ្ញុំចោលហ្នងទៅ ព្រោះខ្ញុំឃើញគេពិបាកពីនោះហើយឲ្យខ្ញុំពិបាកទៀត។

ឃិនៈ គេមាបបំពាក់បំប៉ននយោបាយដែរ?

ហ៊ុយៈ បំពាក់បំប៉ន

ពីរីនៈ ពូជាប់ហ្នឹងរយៈពេលប៉ុន្មានខែ?

ហ៊ុយៈ ជាប់ហ្នឹងតែជាង១ខែទេ ហើយបានទៅធ្វើស្រែនៅនោះ

ពីរីនៈ ធ្វើស្រែនៅណា?

ហ៊ុយៈ នៅព្រែកជ្រៃ ព្រំដែន

ពីរីនៈ ហើយធ្វើម៉េចបានគេដោះលែងពូមកវិញ?

ហ៊ុយៈ ខ្ញុំមិនដឹងដែរ

ឃិនៈ ១០ខែ បានគេដោះលែងវិញ

ហ៊ុយៈ បាទ

ឃិនៈ ប៉ុនដល់ធ្វើស្រែមានអី ដេកធម្មតា ហូបធម្មតា រកបានអីហូបហ្នឹង មិនមែនជាគុកអីជាប់ខាតទេ កន្លែងអប់រំ

ហ៊ុយៈ ប៉ុនអាអ្នកនិយាយ និយាយខ្លាំងពេក ប្រធានអ្នកយាមមិននេះទេ

ពីរីនៈ ពីណាគេអ្នកនិយាយអញ្ចឹង?

ហ៊ុយៈ មិនដឹងអ្នកណាទេ ពួសូរគេនិយាយ ខ្ញុំនៅក្នុងគុកហើយមិនដឹងទេ ខ្ញុំក៏រកតែយុត្តិធម៌ដែរ សូម្បីតែអ្នកនៅជាមួយខ្ញុំដូចខ្ញុំនិយាយអញ្ចឹង ចឹក ត្រូវគេចាប់ដាក់គុក ខ្ញុំសុំអះអាងហើយប៉េងគ្រី នេះក៏ខ្ញុំសុំឲ្យនៅដែរ ប៉ុន ហ៊ី មិនឲ្យនៅខ្ញុំមិនដឹងទៅតាយ៉ាងម៉េចទៀត

ឃិនៈ ហាន សុំគេដែលត្រូវគេចាប់ហើយ ហានសុំទុកទៀត?

ហ៊ុយៈ ចុះបើអាណិត សុំទុកកសាងសិន ហើយខ្ញុំបើមិនសុំ បើទៅងាប់ហើយ ហើយបើជាប់គុកហើយធ្វើយ៉ាងម៉េចក៏មិនអាចជួយបានដែរ ពេលហ្នឹងបានជួយបាន អត់ទេព្រោះគ្នាច្រើនណាស់ អត់មានអ្នកណាទុកចិត្តអ្នកណាទេ យកការតាមដានរហូត ហើយប្រជុំរាល់ល្ងាច ខ្ញុំសំដីខ្លាំងៗ គេមិនដឹងថាខ្ញុំអាណិតអាសូរគេទេ គេថាខ្ញុំកាច ប៉ុនដល់ខ្ញុំអាណិតអាសូរណាស់ដូច ចឹកអ៊ីឡូឡាជាមួយខ្ញុំ ដល់ហើយស្រាប់តែចងក ខ្ញុំធ្លាក់ថ្លើមគ្មុក អញមួយសារនេះគ្រប់ទឹកទៀតហើយ ខំធានាអះអាង ស្រាប់តែអញ្ចឹងងាប់ហើយ ដល់ហើយ ហ៊ី ហៅខ្ញុំមកថាម៉េច ចឹកចងកម៉េចហែង

យិនៈ ខំធានាឲ្យនៅរស់ទៅចង់កង់រាប់ ចុះខ្ញុំសុំកសាងមិនទាន់បានកសាងផង អញ្ជឹងគេចោទយើងថាការពារអ្នកនឹងទៀត ប៉េងគ្រី ក៏ខ្ញុំការពារទុកដែរ កុំអីជាប់គុកទៀត ចេះតែការពារ ផុតពីយើងវែលឯងដីងហើយ នឹងដកមកធ្វើស្រែជាមួយបង ហ៊ុយ គេចាប់បងហ៊ុយ វារួចខ្លួន បើចាប់ទាំងវាទៀតអស់ហើយ អញ្ជឹងបានពួកនៅហ្នឹងអត់ទេ មួយថ្ងៃកាត់មួយថ្ងៃកោរអញ្ជឹង បើគេចាប់អ្នកណាហើយ ។

ពីរ៉ៃនៈ ចុះពូពេលគេដកហុយចេញពីណាគេចូលជំនួស ហ៊ុយ វិញ?

ហ៊ុយៈ ផល

ពីរ៉ៃនៈ គាត់ទទួលនាទីជំនួស ហ៊ុយ ទាំងអស់ហ្នង ?

ហ៊ុយៈ គាត់កង់រយការពារ គុកទួលស្ទែងមុន ដល់ហើយបានឲ្យទៅនៅកាន់កាប់កន្លែងហ្នឹង

ពីរ៉ៃនៈ ផលឥឡូវទៅណាហើយ?

ហ៊ុយៈ កាលហ្នឹងរត់ទៅព្រៃដែរ មកពីព្រៃរាប់ដែរ អត់មានមកពីព្រៃទេ ថាទៅព្រៃ ច្បាំងគ្នាយ៉ាំងម៉េច ជាក្រុមៗហ្នឹង ច្បាំងគ្នារាប់ ។

ពីរ៉ៃនៈ ច្បាំងគ្នាជាមួយវៀតណាមរាប់ទៅ

ហ៊ុយៈ បាទ

ពីរ៉ៃនៈ អញ្ជឹងពូខ្ញុំអរគុណពូច្រើន ចប់ត្រឹមហ្នឹង

ហ៊ុយៈ បាទ

ពីរ៉ៃនៈ ភូមិនេះភូមិអីគេពូ?

ហ៊ុយៈ ភូមិអន្លង់សាន ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល

យិនៈ ភូមិអន្លង់សាន ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល